**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...៧៧៦...សហវ.ប្រក.អគរ            រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១

# ប្រកាស
## ស្តីពី
## ការកែសម្រួលបញ្ញត្តិប្រការ ១ នៃប្រកាសលេខ ៣៨៧ សហវ.គរ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដាឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករាឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដាឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ៣៨៧ សហវ.គរ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## <u>សម្រេច</u>

**ប្រការ ១.-**

កែសម្រួលបញ្ញត្តិប្រការ ១ នៃប្រកាសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល ដូចមានយោងខាងលើមកជា ÷

“ **ប្រការ ១** ÷ សម្រាប់គោលបំណងនៃប្រកាសនេះ ÷

- **កម្រៃជើងសារ** គឺជាថ្លៃ ឬជាទឹកប្រាក់ដែលយកដោយជើងសារតយ ឬអន្តរការីដែលជាអ្នកជម្រុញឱ្យមានកិច្ចចម្លងការ និងជារឿយៗមិនចេញមុខច្បាស់លាស់ថាជាតំណាងរបស់ភាគីណាមួយឡើយ ។ កម្រៃជើងសារត្រូវបូកបញ្ចូលតែក្នុងករណីដែលកម្រៃនេះជាប់ពាក់ព័ន្ធនឹងការលក់ទំនិញដែលត្រូវកំណត់តម្លៃប៉ុណ្ណោះ ។
- **កម្រៃសេវាពីការទិញ**គឺជាកម្រៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដដោយអ្នកទិញទៅភ្នាក់ងាររបស់ខ្លួន សម្រាប់សេវាតំណាងអ្នកទិញនៅក្រៅប្រទេសដែលទាក់ទងទៅនឹងការទិញទំនិញឱ្យខ្លួន ។
- **តម្លៃគណនា** គឺជាតម្លៃគិតពន្ធគយដែលកំណត់ស្របតាមបញ្ញត្តិជំពូកទី ៧ នៃប្រកាសនេះ ។
- **តម្លៃអនុមាន** គឺជាតម្លៃគិតពន្ធគយដែលកំណត់ស្របតាមបញ្ញត្តិជំពូកទី ៦ នៃប្រកាសនេះ ។
- **កម្រៃ** គឺជាថ្លៃបន្ទុក ការទូទាត់ ឬទឹកប្រាក់ដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដចំពោះបំណុល ។
- **ចំណាយទូទៅ** គឺជាថ្លៃ បន្ទុក និងចំណាយដោយផ្ទាល់ ឬដោយប្រយោលនៃផលិតកម្ម និងការលក់ទំនិញសម្រាប់នាំចេញមកកម្ពុជា ។
- **ទំនិញនៃក្រុម ឬប្រភេទដូចគ្នា គឺជាទំនិញនាំចូលដែល** ÷
  - ក- ស្ថិតនៅក្នុងក្រុម ឬជួរជាមួយគ្នានឹងទំនិញនាំចូលដែលបានផលិតដោយឧស្សាហកម្មជាក់លាក់ណាមួយ ឬក៏ផ្នែកឧស្សាហកម្មមួយ ដោយគិតបញ្ចូលទំនិញដូច ឬ ទំនិញប្រហាក់ប្រហែល ដែលទាក់ទងទៅនឹងទំនិញដែលត្រូវកំណត់តម្លៃគិតពន្ធគយ ។
  - ខ- បាននាំចេញពីប្រទេសណាមួយសម្រាប់គោលបំណងនៃបញ្ញត្តិជំពូកទី ៦ នៃប្រកាសនេះ និងបានផលិត ហើយបាននាំចេញពីប្រទេសដែលទំនិញត្រូវបានកំណត់តម្លៃត្រូវបានផលិត និងបាននាំចេញសម្រាប់គោលបំណងនៃបញ្ញត្តិជំពូកទី ៧ នៃប្រកាសនេះ ។
- **ទំនិញដូច** គឺជាទំនិញនាំចូលដែល ÷
  - ក- ដូចគ្នាលើគ្រប់ទិដ្ឋភាព រួមមាន លក្ខណៈរូប គុណភាព និងកេរ្តិ៍ឈ្មោះ ដូចទំនិញដែលត្រូវបានកំណត់តម្លៃ លើកលែងតែភាពខុសគ្នាបន្តិចបន្តួចផ្នែករូបរាង ដែលមិនប៉ះពាល់ដល់តម្លៃទំនិញ ។
  - ខ- ត្រូវបានផលិតនៅក្នុងប្រទេសនៃទំនិញដែលត្រូវកំណត់តម្លៃ ។
  - គ- ត្រូវបានផលិតដោយផលិតករដូចគ្នានឹងទំនិញដែលត្រូវកំណត់តម្លៃ ។ ទំនិញដែលផលិតដោយផលិតករខុសគ្នា ត្រូវយកមកពិចារណាតែនៅពេលដែលពុំមានទំនិញដែលផលិតដោយផលិតករដូចគ្នាប៉ុណ្ណោះ ។

ឃ- ទំនិញដូចមិនរាប់បញ្ចូលទំនិញនាំចូលដែលស្នាដៃវិស្វកម្ម ស្នាដៃអភិវឌ្ឍន៍ ស្នាដៃសិល្បៈ ស្នាដៃគំនូសប្លង់ ឬគំនូសវាស ដែលធ្វើឡើងនៅកម្ពុជា ហើយត្រូវបានផ្តល់ដោយផ្ទាល់ ឬដោយប្រយោលដោយអ្នកទិញទំនិញនាំចូលទាំងនោះ ដោយមិនគិតថ្លៃ ឬដោយបន្ថយថ្លៃ សម្រាប់ការប្រើប្រាស់ពាក់ព័ន្ធនឹងផលិតកម្ម និងការលក់សម្រាប់នាំចេញនៃទំនិញនាំចូលទាំងនោះ ។

- **ថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដ** នៃទំនិញណាមួយ គឺជាទឹកប្រាក់សរុបដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដដោយអ្នកទិញទៅឱ្យ ឬក៏សម្រាប់ជាប្រយោជន៍ដល់អ្នកលក់ទំនិញនោះ ។
- **ការផលិត** រួមមាន ការដាំដុះ ការចិញ្ចឹម ការផលិត និងការយកចេញពីធរណី ។
- **កម្រៃសេវាពីការលក់** គឺជាកម្រៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដដោយអ្នកលក់ទៅឱ្យភ្នាក់ងាររបស់ខ្លួន សម្រាប់សេវាតំណាងអ្នកលក់នៅក្រៅប្រទេសដែលទាក់ទងនឹងការលក់ទំនិញឱ្យខ្លួន ។
- **ទំនិញប្រហាក់ប្រហែល** គឺជាទំនិញនាំចូលដែល ÷

ក- ស្ទើរតែដូចគ្នានឹងទំនិញដែលត្រូវបានកំណត់តម្លៃ លើសមាសធាតុផ្សំ បំណែក និងលក្ខណៈរូប ហើយអាចជំនួសបានតាមមុខងារ និងក្នុងពាណិជ្ជកម្ម ជាមួយទំនិញដែលត្រូវបានកំណត់តម្លៃទាំងខាងគុណភាព និងកេរ្តិ៍ឈ្មោះ ។

ខ- ត្រូវបានផលិតនៅក្នុងប្រទេសនៃទំនិញដែលត្រូវកំណត់តម្លៃ ។

គ- ត្រូវបានផលិតដោយផលិតករដូចគ្នានឹងទំនិញដែលត្រូវកំណត់តម្លៃ ។ ទំនិញដែលផលិតដោយផលិតករខុសគ្នា ត្រូវយកមកពិចារណាតែនៅពេលដែលពុំមានទំនិញដែលផលិតដោយផលិតករដូចគ្នាប៉ុណ្ណោះ ។

ឃ- ទំនិញប្រហាក់ប្រហែល មិនរាប់បញ្ចូលទំនិញនាំចូលដែលស្នាដៃវិស្វកម្ម ស្នាដៃអភិវឌ្ឍន៍ ស្នាដៃសិល្បៈ ស្នាដៃគំនូសប្លង់ ឬគំនូសវាស ដែលធ្វើឡើងនៅកម្ពុជា ហើយត្រូវបានផ្តល់ដោយផ្ទាល់ ឬដោយប្រយោលដោយអ្នកទិញទំនិញនាំចូលទាំងនោះ ដោយមិនគិតថ្លៃ ឬដោយបន្ថយថ្លៃ សម្រាប់ការប្រើប្រាស់ពាក់ព័ន្ធនឹងផលិតកម្ម និងការលក់សម្រាប់នាំចេញនៃទំនិញនាំចូលទាំងនោះ ។

- **ព័ត៌មានគ្រប់គ្រាន់** អំពីការកំណត់នូវទឹកប្រាក់ណាមួយ ភាពខុសគ្នា ឬការកែតម្រូវមានន័យថាជាព័ត៌មានអាចកំណត់បរិមាណបាន ដែលចែងយ៉ាងច្បាស់លាស់ពីភាពត្រឹមត្រូវនៃទឹកប្រាក់ភាពខុសគ្នា ឬការកែតម្រូវ ។
- **តម្លៃចម្លងការ** គឺជាតម្លៃគិតពន្ធគយដែលកំណត់ស្របតាមបញ្ញត្តិជំពូកទី ២ នៃ[illegible] នៃប្រកាសនេះ ។”

**ប្រការ ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានា ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>ចម្លងជូន៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣
  "ដើម្បីអនុវត្ត"
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីជ្រាប និងសុំកិច្ចសហការផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ